# សេចក្តីបន្ថែម ខ :
# ការប្រើប្រាស់ច្បាប់ដើម្បីទាមទារសិទ្ធិផ្នែកបរិស្ថាន




សិទ្ធិមនុស្ស និងជួនកាលសិទ្ធិផ្នែកបរិស្ថាន( សិទ្ធិទទួលបានបរិស្ថានមួយដែលមានសុវត្ថិភាពនិងសុខភាព ) ត្រូវបានការពារដោយច្បាប់នៃប្រទេសជាច្រើន។ សៀវភៅនេះរួមបញ្ចូលសាច់រឿងជាច្រើនដែលរៀបរាប់ពីរបៀបដែលប្រជាពលរដ្ឋធ្វើការងាររួមគ្នាដើម្បីបង្កើតច្បាប់ថ្មីៗសម្រាប់ការពារសហគមន៍របស់ខ្លួន, ឬទាមទារឲ្យមានការការពារពីច្បាប់ដែលមានស្រាប់។

ផ្នែកមួយនេះរួមបញ្ចូលព័ត៌មានដែលស្តីពីរបៀបប្រើប្រាស់**ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន** ឬបណ្តឹងផ្លូវច្បាប់ ដើម្បីប្រយុទ្ធទាមទារសិទ្ធិផ្នែកបរិស្ថានរបស់អ្នក។ វាក៏មានព័ត៌មានអំពីទីកន្លែងដែលត្រូវស្វែងរកជំនួយអន្តរជាតិប្រសិនបើតុលាការជាតិឬក្នុងតំបន់ និងរដ្ឋាភិបាលមិនការពារអ្នកទេ។

សហគមន៍ដែលតស៊ូដើម្បីការពារបរិស្ថាននិងសុខភាពរបស់ខ្លួន ច្រើនតែប្រឈមមុខនឹងការប្រឆាំង និងអំពើហឹង្សាពីសំណាក់ក្រុមហ៊ុនសាជីវកម្ម ឬរដ្ឋាភិបាលដែលចង់ដណ្តើមយកធនធានធម្មជាតិរបស់ពួកគេ ឬចង់អនុវត្តគម្រោងអភិវឌ្ឍន៍របស់ខ្លួន ទោះបីវាបង្កគ្រោះថ្នាក់យ៉ាងណាក៏ដោយ។ គម្រោងទាំងនេះអាចបណ្តេញប្រជាជនចេញពីដីធ្លី, បង្កការបំពុលយ៉ាងខ្លាំងក្លា, បង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាធារណៈ, ឬបង្កើតសារធាតុពុលដែលបង្កបញ្ហាសុខភាពធ្ងន់ធ្ងរ។ ទាំងអស់នេះគឺជាការរំលោភសិទ្ធិមនុស្ស និងសិទ្ធិផ្នែកបរិស្ថាន។

ជួនកាលសាជីវកម្មធំៗមានប្រាក់និងអំណាចយ៉ាងច្រើន ដែលពួកគេអាចបង្ការរដ្ឋាភិបាលមិនឲ្យទទួលស្គាល់ ឬអនុវត្តច្បាប់នានាដែលការពាររូបអ្នក។ នៅពេលច្បាប់ជាតិគ្មានប្រសិទ្ធភាព អាចមានច្បាប់អន្តរជាតិខ្លះដែលការពារអ្នក និងសហគមន៍របស់អ្នក។ គំនិតដែលថាប្រជាជនមានសិទ្ធិផ្នែកបរិស្ថាន គឺជាផ្នែកថ្មីមួយនៃច្បាប់ ដូច្នេះនៅមានការជជែកវែកញែកអំពីនិយមន័យនៃច្បាប់ទាំងនេះ និងរបៀបនៃការអនុវត្តវាជាក់ស្តែង។ ចំណុចនេះធ្វើឲ្យការតស៊ូផ្លូវច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិបរិស្ថាន គឺមានសារសំខាន់ណាស់។

# ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន

ដោយសារតែឧស្សាហកម្ម និងគម្រោងអភិវឌ្ឍន៍ជាច្រើនបានបង្កការបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន ទើបសព្វថ្ងៃរដ្ឋាភិបាលជាច្រើន ឧស្សាហកម្ម និងទីភ្នាក់ងារអភិវឌ្ឍន៍នានាត្រូវបានតម្រូវឲ្យប្រើប្រាស់ឧបករណ៍មួយក្នុងការសម្រេចចិត្ត និងរៀបចំផែនការ ដែលហៅថា ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន(ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន)។

ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន រៀបរាប់អំពីរបៀបដែលគម្រោងមួយ (ដូចជាការសាងសង់ផ្លូវ ការដ្ឋានរ៉ែ អាកាសយានដ្ឋាន ឬការអភិវឌ្ឍន៍ផ្សេងៗទៀតរបស់ឧស្សាហកម្ម) នឹងប៉ះពាល់ដល់ប្រជាជន សត្វ ដី ទឹក និងគុណភាពខ្យល់ក្នុងតំបន់មួយ យ៉ាងដូចម្តេច។ ការវាយតម្លៃនេះក៏អាចក្រឡេកមើលទៅលើបញ្ហាសង្គមនានា ដូចជាការជម្លៀសប្រជាជន និងការបាត់បង់ធនធានវប្បធម៌ ដូចជាការចិញ្ចឹមជីវិតបែបបុរាណ ទីតាំងប្រវត្តិសាស្ត្រ ឬទីសក្ការៈ ។ល។ ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន ក៏ត្រូវតែផ្តល់យោបល់អំពីមធ្យោបាយដែលមិនសូវបង្កគ្រោះថ្នាក់ផងដែរ ប្រសិនបើគម្រោងមួយនេះត្រូវដំណើរការទៅមុខ។ ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន អាចត្រូវបានបង្កើតឡើងដោយសាជីវកម្មតែឯង ឬអាចបង្កើតដោយសហការជាមួយសហគមន៍ និងមន្ត្រីរដ្ឋាភិបាល។ (សម្រាប់ព័ត៌មានអំពីសហគមន៍ចំនួន២ដែលបានប្រើប្រាស់ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន សូមមើលទំព័រ466 និង561)។

## តើការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន មានដំណើរការយ៉ាងដូចម្តេច

ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន មានសកម្មភាពសំខាន់ៗ២យ៉ាង ៖

១. រៀបរាប់អំពីផលប៉ះពាល់ទាំងនេះ។ ជាធម្មតាវាគឺជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនដែលគ្រប់គ្រងគម្រោង ហើយវាអាចមិនទាមទារការចូលរួមពីសហគមន៍។

២. ការជួបប្រជុំជាសាធារណៈដើម្បីអនុញ្ញាតឲ្យសហគមន៍ដែលរងផលប៉ះពាល់ ធ្វើការវាយតម្លៃលើគម្រោងមុននឹងវាចាប់ផ្តើម។

ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន មានប្រសិទ្ធភាពបំផុតនៅពេលអនុវត្តតាមគោលការណ៍ប្រុងប្រយ័ត្នជាមុន (ទំព័រ32)។ ប្រសិនបើការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន បង្ហាញពីគ្រោះថ្នាក់ដែលអាចកើតឡើងដោយសារគម្រោង នោះគម្រោងនោះគួរត្រូវបានបញ្ឈប់ឬកែប្រែ។ ប៉ុន្តែជាញឹកញាប់ ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន ត្រូវបានគេប្រើប្រាស់ដើម្បីធ្វើឲ្យគម្រោងមួយមើលទៅមិនឃើញថាមានគ្រោះថ្នាក់ ទោះបីគម្រោងនោះនឹងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ប្រជាជននិងបរិស្ថានក្នុងពេលបច្ចុប្បន្នឬពេលអនាគតក៏ដោយ។

ក្រុមហ៊ុនជាច្រើនបានសរសេររបាយការណ៍នៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថានរួចជាស្រេច មុននឹងអញ្ជើញសហគមន៍ឲ្យចូលរួម, ជាជាងការសរសេររបាយការណ៍ដោយមានការចូលរួមពីសហគមន៍។ ជួនកាលក្រុមហ៊ុនទាំងនោះមិនបើកការប្រជុំជាសាធារណៈអំពីការវាយតម្លៃផលប៉ះពាល់លើបរិស្ថានទេ ឬមួយពួកគេរៀបចំការប្រជុំមួយដែលធ្វើឲ្យសហគមន៍ពិបាកនឹងចូលរួម។ នៅពេលដំណើរការនៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន ត្រូវបានធ្វើដោយមិនយុត្តិធម៌ ហើយត្រូវបានឆ្លងការសម្រេចយ៉ាងប្រញាប់ប្រញាល់, នោះភាគច្រើនវាតែងតែនាំឲ្យមានស្ថានភាពមួយដែលគម្រោងនោះអាចចាប់ផ្តើមដំណើរការបាន ប៉ុន្តែសហគមន៍បានធ្វើយុទ្ធនាការទាមទារឲ្យបញ្ឈប់គម្រោងនោះ។ ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន អាចជាឧបករណ៍ដ៏សំខាន់មួយសម្រាប់សហគមន៍និងរដ្ឋាភិបាល ក្នុងការវាយតម្លៃនិងកែលម្អលើគម្រោងអភិវឌ្ឍន៍ដែលបានស្នើសុំនោះ។



# តើសហគមន៍អាចមានឥទ្ធិពលលើការវាយតម្លៃផលប៉ះពាល់លើបរិស្ថានដោយរបៀបណា



ការស្វែងរកព័ត៌មានពីប្រភពផ្សេងៗទៀត(មិនមែនយកតែមកពីក្រុមហ៊ុន) និងការចំណាយពេលចាំបាច់ដើម្បីស្វែងយល់អំពីផលប៉ះពាល់ដែលអាចកើតមានឡើង គឺជាផ្នែកដ៏សំខាន់ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីចូលរួមនៅក្នុងការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន។ ជាធម្មតា ការសម្រេចចិត្តជាច្រើនត្រូវបានធ្វើឡើងរួចទៅហើយ នៅពេលប្រជាជនដែលរងផលប៉ះពាល់ច្រើនបំផុតមានមតិចង់បញ្ចេញ។

ការចូលរួមនៅក្នុងដំណើរការនៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន អាចជួយអប់រំនិងរៀបចំចាត់ចែងសហគមន៍របស់អ្នក ឲ្យកាន់តែមានសមត្ថភាពក្នុងការការពារសុខភាពនិងធនធានរបស់ខ្លួនក្នុងពេលយូរអង្វែង។ បើទោះជាអ្នកមិនអាចបញ្ឈប់គម្រោងដ៏គ្រោះថ្នាក់បានជានិច្ចក៏ដោយ ការអប់រំ និងការរៀបចំសកម្មភាពទាក់ទងនឹងការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន អាចជួយការពារសហគមន៍របស់អ្នកបាន។

### ទាមទារឲ្យមានការចូលរួម

សហគមន៍នានាអាចទាមទារឲ្យមានសំឡេងរបស់ខ្លួននៅក្នុងការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន។ ជួនកាលតុលាការ រដ្ឋាភិបាល ឬទីភ្នាក់ងារអភិវឌ្ឍន៍ នឹងអនុញ្ញាតិឲ្យតំណាងសហគមន៍ចូលរួមក្នុងដំណើរការនៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថានដែរ។ ប្រជាជនក្នុងសហគមន៍អាចចូលរួម ឬអាចស្នើសុំសម្ព័ន្ធមិត្តដូចជាអង្គការមិនមែនរដ្ឋាភិបាល ឬមេធាវី ឲ្យធ្វើជាអ្នកតំណាងពួកគេ។ ប្រសិនបើតំណាងសហគមន៍បានចូលរួមក្នុងដំណើរការនៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន នោះពួកគេអាចរាយការណ៍ប្រាប់សហគមន៍វិញអំពីអ្វីដែលក្រុមហ៊ុនមានគម្រោងធ្វើនិងកំពុងធ្វើ។ ការចូលរួមនេះក៏អាចជួយបង្កើនការយល់ដឹងអំពីសិទ្ធិនិងការទទួលខុសត្រូវរបស់សហគមន៍ ព្រមទាំងអំពីមធ្យោបាយដែលពួកគេអាចបង្ការគ្រោះថ្នាក់ពីគម្រោងមួយ ឬបង្ការមិនឲ្យគម្រោងមួយកើតឡើង។

### ទទួលរបាយការណ៍អំពីការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន

សហគមន៍ទាំងឡាយមានសិទ្ធិមើលឯកសារទាំងមូលអំពីការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន គឺមិនមែនគ្រាន់តែជារបាយការណ៍សង្ខេប ឬមានតែផ្នែកណាមួយទេ។ ជាទូទៅ របាយការណ៍នៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន រួមបញ្ចូលនូវផ្នែកមួយចំនួនដែលមានដូចជា "ការប្រឈមគ្រោះថ្នាក់ផ្នែកសន្តិសុខ" "ការប្រឈមគ្រោះថ្នាក់ផ្នែកសង្គម" "ការប្រឈមគ្រោះថ្នាក់ផ្នែកសុខភាព" និង "តម្លៃនៃការសម្អាត"។ ផ្នែកទាំងនេះអាចរៀបរាប់អំពីបញ្ហានានាដែលក្រុមហ៊ុនអាចនឹងលាក់កំបាំង ជាពិសេសនៅក្នុងការប្រជុំជាសាធារណៈ។

បញ្ហាដែលត្រូវបានរៀបរាប់នៅក្នុងការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន ក៏ដូចជាបញ្ហាដែលមិនត្រូវបានបញ្ចូលនៅក្នុងការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន, អាចត្រូវបានចែករំលែកជាមួយប្រព័ន្ធព័ត៌មាន មន្ត្រីរដ្ឋាភិបាល និងសាធារណជន ដើម្បីជួយបង្កើនការប្រឆាំងនឹងគម្រោងគ្រោះថ្នាក់។ អ្នកក៏អាចចែករំលែកជាមួយអង្គការជាតិនិងអន្តរជាតិ ដូចជាអង្គការសហប្រជាជាតិ ដែលអាចដាក់សម្ពាធលើក្រុមហ៊ុនសាជីវកម្ម ឬរដ្ឋាភិបាលឲ្យឆ្លើយតបចំពោះការបារម្ភរបស់សហគមន៍។

## សហគមន៍ប្រឆាំងនិងការជីករ៉ែ

កសិដ្ឋានតូចមួយក្នុងតំបន់ជូនីន(Junin) មានទេសភាពស្រស់ត្រកាល ដែលស្ថិតនៅក្នុងព្រៃពពកមួយនៃចំណោតភ្នំAndes ក្នុងប្រទេសអេក្វាឌ័រ។ ប្រជាជននៅទីនេះមានជីវភាពក្រីក្រ ប៉ុន្តែពួកគេបានប្រកបរបរចិញ្ចឹមជីវិតដោយសារដីរាប់រយឆ្នាំមកហើយ។ ថ្មីៗនេះ ប្រជាជនក្នុងតំបន់ជូនីន បានប្រឈមមុខនឹងបញ្ហាដ៏ធំបំផុតក្នុងប្រវត្តិសាស្ត្ររបស់ពួកគេ គឺក្រុមហ៊ុនមួយមានគម្រោងជីករណ្តៅរ៉ែស្ពាន់ដ៏ធំបំផុតមួយនៅក្នុងទ្វីបអាមេរិកខាងត្បូង។

នៅពេលក្រុមហ៊ុនជីករ៉ែរបស់ជប៉ុនមួយបានមកដល់តំបន់នេះដើម្បីរុករករ៉ែ ប្រជាជនដឹងថាការជីករ៉ែអាចនាំឲ្យមានការបំពុល។ ប៉ុន្តែក្រុមហ៊ុនរ៉ែបានសន្យាថានឹងសាងសង់ផ្លូវថ្នល់ គ្លីនិកសុខភាព និងសាលារៀន ដូច្នេះប្រជាជនក៏បានអនុញ្ញាតឲ្យពួកគេរុករករ៉ែ។ មិនយូរប៉ុន្មាន ក្រុមហ៊ុននោះបានរកឃើញរ៉ែស្ពាន់ក្នុងបរិមាណដ៏ច្រើន ហើយប្រព័ន្ធទឹករបស់ប្រជាជនក៏ត្រូវបានបំពុលដោយកាកសំណល់រ៉ែ។ ក្នុងពេលដ៏ខ្លី ប្រជាជនបានរងគ្រោះពីការឡើងកន្ទួលស្បែក និងបញ្ហាសុខភាពដទៃទៀត។

សហគមន៍បានទាមទារឲ្យក្រុមហ៊ុនរ៉ែនេះបញ្ឈប់ការបំពុល។ ក្រុមហ៊ុនមិនបានឈប់ទេ ដូច្នេះប្រជាជនក្នុងតំបន់ជូនីនក៏បានធ្វើសកម្មភាពរបស់ខ្លួន។ នៅពេលដែលក្រុមហ៊ុនរ៉ែបានចេញទៅសម្រាកលំហែកាយ អ្នកភូមិរាប់រយនាក់បានចូលទៅក្នុងជំរុំជីករ៉ែ ហើយនាំយកឧបករណ៍ គ្រឿងសង្ហារឹម និងវត្ថុមានតម្លៃដទៃទៀត ទៅទុកឲ្យអាជ្ញាធរ។ បន្ទាប់មកពួកគេក៏ដុតបំផ្លាញជំរុំជីករ៉ែនោះ។ ដោយបានទទួលមេរៀននេះ ក្រុមហ៊ុនក៏បានដកចេញ ប៉ុន្តែក្រោយមកក៏លក់រ៉ែឲ្យទៅក្រុមហ៊ុនមួយទៀតដែលមកពីប្រទេសកាណាដា។




ក្រុមហ៊ុនកាណាដានេះបានធ្វើការងារដើម្បីបំបែកបំបាក់សហគមន៍។ ពួកគេទិញដីប្រជាជនក្នុងតម្លៃថ្លៃ។ ប្រជាជនខ្លះយល់ព្រមលក់ដីរបស់ខ្លួន រីឯខ្លះទៀតមិនព្រម។ ក្រុមហ៊ុនដឹងថាធ្វើបែបនេះពួកគេនឹងឈ្លោះប្រកែកគ្នា។ ក្រុមហ៊ុនក៏បានបញ្ជូនគ្រូពេទ្យឲ្យមកផ្តល់ការថែទាំសុខភាពដល់ប្រជាជនណាដែលចុះហត្ថលេខាលើលិខិតមួយដែលបញ្ជាក់ថាពួកគេគាំទ្រសកម្មភាពរបស់ក្រុមហ៊ុនរ៉ែ។ បន្ទាប់ពីភាពអយុត្តិធម៌នេះត្រូវបានឮទៅដល់ក្រៅប្រទេសអេក្វាឌ័រ សហគមន៍អន្តរជាតិបានបញ្ជូនបុគ្គលិកសុខាភិបាលមកផ្តល់ការថែទាំជូនប្រជាជនគ្រប់គ្នាដែលមានជំងឺ។

ដោយសារច្បាប់ក្នុងប្រទេសអេក្វាឌ័រទាមទារឲ្យមានការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន មុននឹងគម្រោងមួយអាចដំណើរការបាន ដូច្នេះប្រជាជនក្នុងតំបន់ជូនីនបានយកការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន ធ្វើជាផ្នែកមួយនៃផែនការការពារដីធ្លីរបស់ពួកគេ។ អ្នកភូមិបានដឹងថា ប្រសិនបើការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន ត្រូវបានធ្វើឡើងមិនបានត្រឹមត្រូវទេ រដ្ឋាភិបាលនឹងមិនអនុញ្ញាតឲ្យសាងសង់ការដ្ឋានរ៉ែឡើយ។ ពួកគេក៏ដឹងដែរថា ការវាយតម្លៃផលប៉ះពាល់លើបរិស្ថានដោយស្មោះត្រង់ នឹងបង្ហាញពីការបណ្តេញប្រជាជនចេញពីដីធ្លី, ការបំពុលខ្យល់, សំណឹកដី និងនាំដីល្បាប់មកចាក់, និងការបំពុលទឹកដោយសារការបង្ហូរលោហៈធ្ងន់ និងកាកសំណល់ពុលដទៃទៀត។

(សាច់រឿងតទៅទំព័របន្ទាប់)។

(តមកពីទំព័រមុន)



ប្រជាជនក្នុងតំបន់ជូនីនបានរៀនពីរបៀបប្រើប្រាស់ច្បាប់ដើម្បីការពារខ្លួន។ បន្ទាប់ពីក្រុមហ៊ុនអះអាងថាខ្លួនបានបញ្ចប់របាយការណ៍នៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថានរួចហើយ រដ្ឋាភិបាលបានបដិសេធដោយនិយាយថារបាយការណ៍នោះមិនទាន់ពេញលេញ។

ប្រជាជនក៏បានធ្វើសកម្មភាពដោយផ្ទាល់ផងដែរ ដូចជារារាំងមិនឲ្យក្រុមហ៊ុនចូលមកក្នុងតំបន់ តាមរយៈការបិទផ្លូវ។ អ្នកដឹកនាំសហគមន៍ទាំងឡាយបានប្រកាសថា ទីក្រុងទាំងមូលមិនមែនជាតំបន់ជីករ៉ែឡើយ។ តាមរយៈការប្រើប្រាស់យុទ្ធសាស្ត្រផ្សេងៗជាច្រើន ប្រជាជនក្នុងតំបន់ជូនីនបានបង្ការមិនឲ្យរណ្តៅរ៉ែស្ពាន់នេះបំផ្លាញផ្ទះសម្បែង ព្រៃឈើក្រាស់ឃ្មឹក និងប្រភពទឹករបស់ពួកគេឡើយ។

# ការវាយតម្លៃក្នុងសហគមន៍ពីផលប៉ះពាល់លើបរិស្ថាន

ការវាយតម្លៃក្នុងសហគមន៍ពីផលប៉ះពាល់លើបរិស្ថាន អាចជួយប្រជាជននៅក្នុងភូមិ ទីក្រុង ឬតំបន់មួយ ឲ្យមានការយល់ដឹងរួមគ្នាអំពីមធ្យោបាយដែលពួកគេប្រើប្រាស់, ការពារ, និងអាស្រ័យលើធនធាននានា ដូចជាខ្យល់ អាហារ ទឹក សត្វ ផលិតផលព្រៃឈើ ឱសថរុក្ខជាតិ ទីសក្ការៈ ។ល។ បែបនេះអាចបង្កើតជាដំណើរការមួយដើម្បីដោះស្រាយជម្លោះនិងការយល់ច្រឡំចំពោះគ្នាទាក់ទិននឹងការប្រើប្រាស់ធនធាន។ ដំណើរការនេះអាចជួយបង្កើតសាមគ្គីភាពចាំបាច់ក្នុងការតតាំងជាមួយក្រុមហ៊ុនឬរដ្ឋាភិបាល។ វាក៏អាចជួយរៀបចំសកម្មភាពប្រជាជនឲ្យប្រឆាំងនឹងឧស្សាហកម្មដែលយកចំណេញលើការបែកបាក់គ្នារវាងប្រជាជន ដើម្បីឆ្លៀតឱកាសកេងប្រវ័ញ្ចលើទឹក ឈើ ដីធ្លី ឬធនធានផ្សេងៗរបស់ពួកគេ។

ការវាយតម្លៃក្នុងសហគមន៍ពីផលប៉ះពាល់លើបរិស្ថាន អាចជាការពិភាក្សាយ៉ាងសាមញ្ញអំពីធនធានដែលសហគមន៍ប្រើប្រាស់ រួចឈានដល់ការព្រមព្រៀងមួយលើរបៀបការពារធនធានរបស់ខ្លួនឲ្យបានល្អបំផុត។ ការវាយតម្លៃដ៏ស្មុគស្មាញថែមទៀត អាចរួមបញ្ចូលទាំងផែនទីលម្អិត ការស្ទង់មតិប្រជាជន ព្រមទាំងការចងសម្ព័ន្ធភាពជាមួយសហគមន៍ជិតខាងនិងអង្គការនានាដែលគាំទ្រពួកគេ។

ការវាយតម្លៃក្នុងសហគមន៍ពីផលប៉ះពាល់លើបរិស្ថាន មានលក្ខណៈខុសគ្នាពីការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន ដែលត្រូវបានសិក្សាដោយក្រុមហ៊ុនឬរដ្ឋាភិបាល។ វាអាចមិនបំពេញគ្រប់តម្រូវការផ្លូវការនៃ ការវាយតម្លៃផលប៉ះពាល់លើបរិស្ថានទេ ប៉ុន្តែវាមានបន្ថែមនូវចំណុចសំខាន់ៗផ្សេងទៀត ដូចជា គំនិតរបស់សហគមន៍ ព្រមទាំងសុខភាពនិងវប្បធម៌របស់ប្រជាជន ជាជាងការទាញយកធនធាន។ ការវាយតម្លៃក្នុងសហគមន៍ពីផលប៉ះពាល់លើបរិស្ថាន សម្គាល់ឃើញថា រចនាសម្ព័ន្ធដ៏ពិបាកយល់ និងភាសាវិទ្យាស្រ្តដ៏ស្មុគស្មាញ ដែលត្រូវបានទាមទារនៅក្នុងការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន គឺមិនត្រឹមតែធ្វើឲ្យប្រជាជនភាគច្រើនភ័ន្តច្រឡំប៉ុណ្ណោះទេ ប៉ុន្តែគឺវាត្រូវបានទាមទារយ៉ាងដូច្នេះដោយមានចេតនា ព្រោះដើម្បីផាត់ចោលពួកគេចេញពីក្នុងដំណើរការនេះ។ ការវាយតម្លៃក្នុងសហគមន៍ពីផលប៉ះពាល់លើបរិស្ថាន គឺជាវិធីមួយនៃក្នុងការនិយាយថា "មធ្យោបាយមួយទៀតក្នុងការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន គឺជាដំណើរការដែលអាចធ្វើទៅរួច"។

សកម្មភាពជាច្រើននៅក្នុងសៀវភៅនេះ ដូចជាការគូរផែនទី(ទំព័រ15) ល្ខោនសង្គម(ទំព័រ18) ការស្ទង់មតិផ្នែកសុខភាព(ទំព័រ500) សកម្មភាពការពារទីជម្រាល(ទំព័រ164) ការដើរសង្កេតមើលសំរាម(ទំព័រ391) ឬសកម្មភាពផ្សេងៗទៀតដែលបានបង្កើតឡើងនៅក្នុងសហគមន៍របស់អ្នក អាចរួមចំណែកក្នុងការវាយតម្លៃក្នុងសហគមន៍ពីផលប៉ះពាល់លើបរិស្ថាន។

# បណ្ដឹងផ្លូវច្បាប់




មធ្យោបាយមួយដែលសិទ្ធិនិងយុត្តិធម៌ផ្នែកបរិស្ថាន អាចទទួលបានជ័យជំនះ គឺតាមរយៈការឡើងតុលាការប្ដឹងក្រុមហ៊ុនដែលបានរំលោភលើច្បាប់ជាតិឬអន្ដរជាតិ។ បណ្ដឹងផ្លូវច្បាប់ជោគជ័យប្រឆាំងនឹងឧស្សាហកម្មឬក្រុមហ៊ុនដែលបំពុល មិនត្រឹមតែការពារប្រជាជនដែលរងផលប៉ះពាល់ដោយផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្ដែវាក៏បានការពារប្រជាជននៅទីកន្លែងផ្សេងទៀតនិងប្រជាជនក្នុងជំនាន់ក្រោយផងដែរ។

## តើបណ្ដឹងផ្លូវច្បាប់នឹងជួយសហគមន៍ឬទេ?

បណ្ដឹងផ្លូវច្បាប់ត្រូវបានប្រើប្រាស់យ៉ាងជោគជ័យក្នុងការតស៊ូជាច្រើនដើម្បីយុត្តិធម៌ផ្នែកបរិស្ថាន។ ប៉ុន្ដែបណ្ដឹងផ្លូវច្បាប់ត្រូវការចំណាយប្រាក់យ៉ាងច្រើន ហើយជាញឹកញាប់វាត្រូវការពេលវេលាជាច្រើនឆ្នាំ។

សូម្បីតែប្រទេសមួយដែលមានច្បាប់សម្រាប់ការពារសុខភាពនិងបរិស្ថានក៏ដោយ ការយកឈ្នះនៅក្នុងតុលាការអាចជាការពិបាក។ ប្រសិនបើច្បាប់នោះមិនត្រូវបានប្រើប្រាស់ញឹកញាប់ទេ ចៅក្រមនិងមេធាវីប្រហែលជាមិនយល់ដឹងពីវាច្បាស់។ ហើយនៅក្នុងប្រទេសជាច្រើន ជាពិសេសប្រទេសដែលក្រុមហ៊ុនមានអំណាចខ្លាំង អំពើពុករលួយក្នុងចំណោមចៅក្រមនិងអ្នកនយោបាយ ធ្វើឲ្យសហគមន៍ក្រីក្រពិបាកនឹងទាមទារសិទ្ធិរបស់ខ្លួនណាស់។ ជាអកុសល បណ្ដឹងផ្លូវច្បាប់ដែលបរាជ័យ មានច្រើនជាងបណ្ដឹងផ្លូវច្បាប់ដែលជោគជ័យ។

មុននឹងចាប់ផ្ដើមបណ្ដឹងផ្លូវច្បាប់ប្រឆាំងនឹងក្រុមហ៊ុនសាជីវកម្មឬរដ្ឋាភិបាល គួរពិចារណាលើចំណុចទាំងនេះ។

### គិតអំពីគោលដៅរបស់អ្នក

ជាការសំខាន់គឺអ្នកត្រូវដឹងឲ្យច្បាស់ថា តើអ្នកចង់ឲ្យបណ្ដឹងផ្លូវច្បាប់នោះសម្រេចបានអ្វី។ បន្ទាប់មក សម្រេចចិត្តថាតើបណ្ដឹងផ្លូវច្បាប់ពិតជាមធ្យោបាយល្អបំផុតក្នុងការឈានដល់គោលដៅនោះមែនឬ។ តើអ្នកចង់ឲ្យក្រុមហ៊ុន :

- សម្អាតប្រេងកំពប់ ឬការបំពុលដោយសារធាតុពុលផ្សេងទៀតឬ?
- បង់ប្រាក់សំណងលើការខូចខាតលើសុខភាព ដីធ្លី ឬធនធាន?
- បិទ និងចេញពីតំបន់ឬប្រទេសរបស់អ្នក?

ការតស៊ូផ្លូវច្បាប់អាចបង្កើតចលនានិងអប់រំសហគមន៍។ ប៉ុន្ដែសកម្មភាពដូចជា ការធ្វើពហិការ អង្គុយមួយកន្លែង បាតុកម្ម ឬយុទ្ធនាការព័ត៌មានសាធារណៈ អាចនាំឲ្យមានការចរចារ ឬការដោះស្រាយផ្នែកនយោបាយឆាប់រហ័សជាងនិងងាយជាងការតស៊ូផ្លូវច្បាប់ដ៏យូរអង្វែង។ គួរពិចារណាមើលថា សម្រាប់សហគមន៍របស់អ្នក តើសកម្មភាពទាំងនេះងាយជាងនិងមានប្រសិទ្ធភាពជាងបណ្ដឹងផ្លូវច្បាប់ឬទេ។ ម្យ៉ាងទៀត គួរពិចារណាផងដែរ ថាតើការប្រើប្រាស់ទាំងសកម្មភាពផ្លូវច្បាប់ និងសកម្មភាពដោយផ្ទាល់ ព្រមគ្នា នឹងជួយសហគមន៍របស់អ្នកឲ្យទទួលបានជោគជ័យដែរឬយ៉ាងណា។

### តើបណ្ដឹងផ្លូវច្បាប់មានប្រយោជន៍ឬទេ ប្រសិនបើវាមិនទទួលបានជោគជ័យក្នុងតុលាការ?

ជាការពិត អ្នកចង់ឈ្នះលើបណ្ដឹងផ្លូវច្បាប់របស់អ្នក។ ប៉ុន្តែប្រសិនបើអ្នកមិនប្រាកដថាអ្នកនឹងទទួលបានជោគជ័យទេ គួរពិចារណាថា តើវានឹងជួយឬផ្ដល់គ្រោះថ្នាក់ថែមទៀតប្រសិនបើវាមិនឈ្នះ។ ជួនកាលបណ្ដឹងផ្លូវច្បាប់ដែលបរាជ័យ អាចទាញចំណាប់អារម្មណ៍ពីសាធារណៈជនឲ្យពិចារណាទៅលើបញ្ហារបស់សហគមន៍។ ប្រសិនបើបណ្ដឹងផ្លូវច្បាប់ដែលទាក់ទងនឹងការបំផ្លាញបរិស្ថាន និងការរំលោភសិទ្ធិមនុស្សមិនបានទទួលជោគជ័យនៅក្នុងតុលាការប្រទេសអ្នកទេ អ្នកអាចប្ដឹងបន្តទៅអង្គការអន្តរជាតិ ដូចជា គណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិកាំង ឬអង្គការសហប្រជាជាតិ(មើលទំព័រ567)។ បែបនេះអាចនៅតែដោះស្រាយបញ្ហាមិនបានដដែល ប៉ុន្តែវាអាចទាញចំណាប់អារម្មណ៍នៃពិភពលោកមកលើបញ្ហារបស់អ្នក។ ប៉ុន្តែវាក៏ត្រូវការពេលវេលានិងធនធានកាន់តែច្រើនថែមទៀត។

ជួនកាល បណ្ដឹងផ្លូវច្បាប់ដែលបរាជ័យ អាចធ្វើឲ្យមានបញ្ហាកាន់តែធំ។ លទ្ធផលមិនល្អ អាចនាំឲ្យចៅក្រមនិងមេធាវីគិតថា បណ្ដឹងផ្លូវច្បាប់នៅថ្ងៃមុខទៀត មិនគួរទទួលជ័យជំនះដូចគ្នា។ ការផ្សព្វផ្សាយជាសារធារណៈអំពីចំណុចអវិជ្ជមាន អាចធ្វើឲ្យប្រជាជនគិតថា សហគមន៍នោះទាមទារប្រាក់ឬរង្វាន់ដទៃទៀតដោយមិនយុត្តិធម៌។ បណ្ដឹងផ្លូវច្បាប់ដែលបរាជ័យ អាចធ្វើឲ្យសហគមន៍មួយបាត់បង់ភាពថ្លៃថ្នូរ និងបែកបាក់គ្នា។

### តើនរណានឹងនាំយកបណ្ដឹងផ្លូវច្បាប់ទៅតុលាការ?

ជនរងគ្រោះ មិនថាជាមនុស្សម្នាក់ គ្រួសារមួយ ឬសហគមន៍ទាំងមូលទេ ត្រូវតែមានឆន្ទៈទទួលយកកិច្ចការនេះ ព្រមទាំងការប្រឈមគ្រោះថ្នាក់ពីបណ្ដឹងនេះ។ ជាធម្មតា អង្គការមួយមិនអាចនាំយកបណ្ដឹងផ្លូវច្បាប់ប្រឆាំងនឹងក្រុមហ៊ុនមួយ ជំនួសជនរងគ្រោះទេ ប៉ុន្តែអាចជំនួសជនដែលគ្មានឆន្ទៈចូលរួមក្នុងបណ្ដឹងនោះ។

### តើមានភស្តុតាងនៃការបង្កគ្រោះថ្នាក់ឬទេ?

ដើម្បីឲ្យបណ្ដឹងមួយទទួលជោគជ័យ អ្នកត្រូវតែអាចបញ្ជាក់ថា :

- ជនរងគ្រោះបានរងគ្រោះថ្នាក់ផ្លូវកាយឬផ្នែកសេដ្ឋកិច្ច។
- ក្រុមហ៊ុនសាជីវកម្មបានបង្កគ្រោះថ្នាក់ ឬជាអ្នកទទួលខុសត្រូវលើគ្រោះថ្នាក់នោះ។

ប្រសិនបើគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់បញ្ជាក់លើចំណុចនេះទេ បណ្ដឹងផ្លូវច្បាប់អាចផ្ដល់ផលអាក្រក់ច្រើនជាងល្អ។ សូម្បីតែថាក្រុមហ៊ុនមួយបានរំលោភច្បាប់យ៉ាងច្បាស់មែន ប៉ុន្តែប្រសិនបើគ្មានភស្តុតាងបញ្ជាក់ថាពួកគេបង្កគ្រោះថ្នាក់ទេ អ្នកប្រហែលជាមិនត្រូវបានអនុញ្ញាតឲ្យនាំយកករណីនេះទៅតុលាការទេ ហើយប្រសិនបើអ្នកធ្វើដូច្នេះ នោះអ្នកប្រហែលជាមិនទទួលបានជ័យជំនះឡើយ។

### តើមានភស្តុតាងឬទេ?

មានតែភស្តុតាងណាដែលអាចនាំយកទៅតុលាការទេ ដែលជាភស្តុតាងមានប្រយោជន៍នៅក្នុងតុលាការ។ ប្រជាជនដែលនាំយកបណ្ដឹងផ្លូវច្បាប់ដោយសារតែពួកគេបានរងគ្រោះថ្នាក់ ត្រូវតែមានឆន្ទៈនិងអាចនិយាយនៅក្នុងតុលាការ ហើយពួកគេត្រូវតែមានសាក្សីដែលមានឆន្ទៈនិយាយផងដែរ។ ពួកគេត្រូវតែអាចបង្ហាញភស្តុតាងតាមរយៈរូបភាព ការសិក្សា កំណត់ត្រាពេទ្យ ឬភស្តុតាងដទៃទៀតដែលបញ្ជាក់ថាក្រុមហ៊ុននោះពិតជាបានបង្កគ្រោះថ្នាក់មែន។ ការបញ្ជាក់អំពីគ្រោះថ្នាក់ អាចជាការពិបាកណាស់។ឧទាហរណ៍ ក្រុមហ៊ុនអាចជួលគ្រូពេទ្យម្នាក់ឲ្យនិយាយថា ជំងឺមហារីកដែលកើតឡើងក្នុងចំណោមកម្មករ គឺមិនមែនមកពីសារធាតុគីមីដែលក្រុមហ៊ុនបានប្រើប្រាស់ទេ ប៉ុន្តែដោយសារកម្មករខ្លួនឯងមានទម្លាប់មិនល្អ ដូចជាការជក់បារី ការបរិភោគរបបអាហារមិនល្អ ឬសំណាងអាក្រក់។ ការបញ្ជាក់ឲ្យត្រឹមត្រូវតាមផ្លូវច្បាប់អំពី "ហេតុ និងផល" អាចជាការពិបាកណាស់ បើទោះជាយើងមើលទៅឃើញថាច្បាស់ណាស់ទៅហើយ។

## តើនរណា ឬអ្វី ដែលបង្កគ្រោះថ្នាក់?

បណ្ដឹងផ្លូវច្បាប់អាចត្រូវបានធ្វើឡើងប្រឆាំងនឹងប្រជាជន ក្រុមហ៊ុនសាជីវកម្ម និងរដ្ឋាភិបាល ថាបានបំផ្លាញបរិស្ថាន។

## តើបណ្ដឹងផ្លូវច្បាប់នេះប្រឆាំងនឹងសាជីវកម្មពហុសាសន៍ឬ?

សាជីវកម្មពហុសាសន៍ ភាគច្រើនមានការិយាល័យនៅក្នុងប្រទេសជាច្រើន។ ដើម្បីប្ដឹងសាជីវកម្មពហុសាសន៍ឲ្យបានជោគជ័យ អ្នកចាំបាច់ត្រូវធ្វើការទាំងនៅក្នុងប្រទេសដែលរងគ្រោះ និងប្រទេសកំណើតនៃសាជីវកម្មនោះ។ បែបនេះអាចត្រូវចំណាយយ៉ាងច្រើន និងពិបាកខ្លាំងណាស់ ប៉ុន្តែវាអាចធ្វើទៅរួច(មើលសាច់រឿងនៅទំព័រ494 និង522)។



ក្រុមហ៊ុនពហុសាសន៍ ភាគច្រើនមានសាខាជាច្រើននៅប្រទេសផ្សេងៗដែលពួកគេធ្វើការ។ ការប្ដឹងសាខាក្រុមហ៊ុននៅក្នុងប្រទេសមួយ អាចមានភាពងាយស្រួលជាងការប្ដឹងម្ចាស់ក្រុមហ៊ុនដែលនៅក្រៅប្រទេស។ ឧទាហរណ៍ នៅពេលក្រុមហ៊ុនអាមេរិក ឆេវរ៉ុន បានបំពុលដែនដីសណ្ដរនីហ្សេក្នុងប្រទេសនីហ្សេរីយ៉ា សកម្មជនក្នុងតំបន់បានប្ដឹងសាខាក្រុមហ៊ុនឆេវរ៉ុនដែលមានទីតាំងក្នុងប្រទេសនីហ្សេរីយា ជាជាងប្ដឹងក្រុមហ៊ុនអាមេរិកធំ។ ក្នុងពេលជាមួយគ្នា សកម្មជននៅតាមប្រទេសខាងក្រៅ បានចាប់ផ្ដើមយុទ្ធនាការមួយដើម្បីអប់រំប្រជាជននៅជុំវិញពិភពលោក អំពីការរំលោភសិទ្ធិមនុស្សរបស់ក្រុមហ៊ុនឆេវរ៉ុន ដើម្បីដាក់សម្ពាធលើក្រុមហ៊ុននេះឲ្យផ្លាស់ប្ដូរការអនុវត្តរបស់ខ្លួន។

## ចំណុចផ្សេងៗទៀតដែលគួរពិចារណា

- តើគ្រោះថ្នាក់ ឬការរំលោភ ទើបបានប្រព្រឹត្តឡើងថ្មីៗនេះឬ? បណ្ដឹងផ្លូវច្បាប់ត្រូវតែធ្វើឡើងក្នុងអំឡុងពេលជាក់លាក់មួយបន្ទាប់ពីគ្រោះថ្នាក់បានកើតឡើង(ជាធម្មតាមិនលើសពី១០ឆ្នាំ)។ បែបនេះធ្វើឲ្យអ្នកពិបាកនឹងយកឈ្នះក្ដីពាក់ព័ន្ធនឹងជំងឺដែលត្រូវការពេលវេលាច្រើនឆ្នាំក្នុងការវិវឌ្ឍន៍ដូចជាជំងឺមហារីកជាដើម ទោះបីវាជាជំងឺដែលធ្ងន់ធ្ងរបំផុតក៏ដោយ។
- តើប្រជាជនដែលនាំយកបណ្ដឹងផ្លូវច្បាប់ សាក្សីរបស់ពួកគេ និងមេធាវីរបស់ពួកគេ ពិតជាមានឆន្ទៈប្រថុយនឹងសុវត្ថិភាពរបស់ខ្លួនឬទេ? សាជីវកម្មនិងរដ្ឋាភិបាលជាច្រើន នឹងមិនព្រមបញ្ឈប់សកម្មភាពរបស់ខ្លួនឡើយ ក្នុងការការពារអំណាចរបស់ខ្លួន ទោះបីត្រូវប្រើអំពើហិង្សា ឬឃាតកម្មក៏ដោយ។ អ្នកដែលតស៊ូនឹងអំណាចរបស់ពួកគេ អាចប្រឈមគ្រោះថ្នាក់ដល់ជីវិត។
- តើមានប្រាក់សម្រាប់ចំណាយក្នុងបណ្ដឹងផ្លូវច្បាប់នេះឬទេ? ចំណាយក្នុងតុលាការ ការចំណាយលើមេធាវី ការធ្វើដំណើរឆ្លងប្រទេស ទូរស័ព្ទ ការប្រមូលភស្តុតាង និងការចំណាយដទៃទៀត បូកសរុបទៅនឹងមានតម្លៃយ៉ាងខ្ពស់។
- តើអ្នកអាចធ្វើការងារជាច្រើនឆ្នាំ ទាក់ទងនឹងបណ្ដឹងនេះឬទេ? បណ្ដឹងផ្លូវច្បាប់មួយអាចត្រូវការពេលវេលាពី៣ទៅ១០ឆ្នាំ ឬច្រើនជាងនេះទៀត។ ជួនកាល ជនរងគ្រោះបានស្លាប់រួចទៅហើយនៅពេលករណីច្បាប់ត្រូវបានដោះស្រាយ។

# ការប្រើប្រាស់ច្បាប់អន្តរជាតិ

ច្បាប់និងអនុសញ្ញាជាច្រើនដែលបានព្រមព្រៀងដោយប្រជាជនសមាជិកនៃអង្គការសហប្រជាជាតិ( ស្ទើរតែគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក ) ការពារសិទ្ធិផ្នែកបរិស្ថានសម្រាប់មនុស្សគ្រប់រូប។ សិទ្ធិមនុស្សជាកម្មសិទ្ធិរបស់មនុស្សគ្រប់គ្នានិងសហគមន៍ទាំងឡាយ ហើយមិនអាចដកយកវិញបានឡើយ។ សិទ្ធិទាំងនេះត្រូវបានទទួលស្គាល់ជាអន្តរជាតិ ប៉ុន្តែដើម្បីឲ្យសិទ្ធិទាំងនេះមានប្រសិទ្ធភាព ប្រជាជនត្រូវតែយល់ដឹងពីវាឲ្យបានច្បាស់ ព្រមទាំងអនុវត្តសិទ្ធិរបស់ខ្លួន។ បើគ្មានការធ្វើសកម្មភាពដើម្បីប្រាកដថាសិទ្ធិទាំងនេះត្រូវបានអនុវត្តនៅថ្នាក់ជាតិទេ ច្បាប់និងអនុសញ្ញាអន្តរជាតិមិនមានប្រសិទ្ធភាពឡើយ។




## កិច្ចព្រមព្រៀងអន្តរជាតិ

កិច្ចព្រមព្រៀងអន្តរជាតិជាច្រើន ការពារសិទ្ធិមនុស្ស និងបរិស្ថាន។ ជាអកុសល មនុស្សម្នាក់ឬមនុស្សមួយក្រុម មិនអាចប្តឹងបានទេនៅពេលកិច្ចព្រមព្រៀងទាំងនេះត្រូវបានរំលោភ។ មានតែប្រទេសហត្ថលេខីប៉ុណ្ណោះ ដែលអាចប្តឹងបាន ហើយពួកគេកម្រនឹងធ្វើបែបនេះណាស់។ ម្យ៉ាងទៀត កិច្ចព្រមព្រៀងទាំងនេះអាចអនុវត្តប្រឆាំងនឹងរដ្ឋាភិបាលប៉ុណ្ណោះ គឺមិនមែនប្រឆាំងនឹងសាជីវកម្មពហុសាសន៍ទេ។ នៅប្រទេសជាច្រើន ច្បាប់អន្តរជាតិអាចត្រូវបានប្រើប្រាស់នៅក្នុងតុលាការប្រទេសនោះ។ ការស្វែងយល់អំពីអ្វីដែលកិច្ចព្រមព្រៀងអន្តរជាតិបានចែង ក៏អាចជួយអ្នកផងដែរឲ្យយល់អំពីឥរិយាបទនៃសហគមន៍អន្តរជាតិចំពោះបញ្ហាជាក់លាក់មួយ ព្រមទាំងអាចជួយបង្កើតយុទ្ធនាការផ្សេងៗដើម្បីការពារសិទ្ធិមនុស្ស។

ប្រសិនបើប្រជាជនយល់ដឹងច្បាស់ពីសិទ្ធិរបស់ខ្លួន និងពីកិច្ចព្រមព្រៀងដែលប្រទេសជាច្រើនបានឯកភាពក្នុងការការពារពួកគេ នោះពួកគេអាចអនុវត្តសិទ្ធិរបស់ខ្លួនកាន់តែប្រសើរ និងទាមទារឲ្យរដ្ឋាភិបាលមានភាពទទួលខុសត្រូវ។

នេះគឺជាបញ្ជីដែលរៀបរាប់ពីកិច្ចព្រមព្រៀងអន្តរជាតិដែលការពារសិទ្ធិមនុស្ស និងបរិស្ថាន រួមជាមួយ
គេហទំព័រដែលអ្នកអាចស្វែងរកព័ត៌មានអំពីកិច្ចព្រមព្រៀងទាំងនោះ និងអំពីរបៀបប្រើប្រាស់វា។
(មើលទំព័រ467 សម្រាប់ការបរិយាយអំពីកិច្ចព្រមព្រៀងមួយចំនួនដែលទាក់ទងនឹងសារធាតុពុល)។

**The United Nations Charter**
www.un.org/aboutun/charter/

**The Universal Declaration of Human Rights**
www.un.org/Overview/rights.html

**The Convention on the Rights of the Child**
www.unhchr.ch/html/menu3/b/k2crc.htm
www.unicef.org/crc/

**The United Nations Framework Convention on Climate Change**
unfccc.int/2860.php

**The Convention on Biological Diversity**
www.biodiv.org/default.shtml
www.iisd.ca/biodiv/cbdintro.html

**The Declaration on the Right to Development**
www.unhchr.ch/html/menu3/b/74.htm

**The International Covenant on Economic, Social and Cultural Rights**
www.unhchr.ch/html/menu3/b/a_cescr.htm

**The United Nations Declaration on Social Progress and Development**
www.unhchr.ch/html/menu3/b/m_progre.htm

**The United Nations Vancouver Declaration on Human Settlements**
www.un-documents.net/van-dec.htm

**The Stockholm Convention on the Elimination of POPS**
www.pops.int
www.ipen.org

**The Basel Convention on the Control of Transboundary Movements of Hazardous Wastes and Their Disposal**
www.basel.int/text/con-e.htm
www.ban.org

**The Bamako Convention on the Ban of the Import into Africa and the Control of Transboundary Movement of Hazardous Wastes within Africa**
www.londonconvention.org/Bamako.htm
www.ban.org/Library/bamako_treaty.htm

**The Rotterdam Convention on the Prior Informed Consent (PIC) Procedure for Certain Hazardous Chemicals and Pesticides in International Trade**
www.pic.int/

**The Convention on the Prevention of Marine Pollution by Dumping of Wastes and Other Matter**
www.imo.org/Conventions/contents.asp?topic_id=258&doc_id=681
www.londonconvention.org

**The Dublin Statement on Water and Sustainable Development**
www.wmo.ch/web/homs/documents/english/icwedece.html

**The Millennium Declaration of Johannesburg**
www.johannesburgsummit.org/html/documents/summit_docs/political_declaration_final.pdf

## វេទិកាអន្តរជាតិ និងទម្រង់ការពិសេស

ដើម្បីទាញចំណាប់អារម្មណ៍មកលើការតស៊ូដើម្បីសិទ្ធិមនុស្ស ប្រជាជនក្នុងប្រទេសជាច្រើនបានស្វែងរកយុត្តិធម៌នៅតាមវេទិកាផ្លូវច្បាប់អន្តរជាតិ ដូចជាអង្គការសហរដ្ឋអាមេរិកនៃតុលាការអន្តរអាមេរិកាំង តុលាការពិភពលោក និងគណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ ចំណាប់អារម្មណ៍អន្តរជាតិនៅក្នុងវេទិកាទាំងនេះ អាចដាក់សម្ពាធលើប្រទេសទាំងនោះឲ្យចរចាររកដំណោះស្រាយ ឬបញ្ឈប់សកម្មភាពរបស់ក្រុមហ៊ុនសាជីវកម្មដែលបង្កការខូចខាតដល់បរិស្ថាន និងរំលោភសិទ្ធិមនុស្ស។

វាអាចជាការចាំបាច់ដែលត្រូវបង្ហាញថា ការឡើងទៅតុលាការនៅក្នុងប្រទេសដែលការរំលោភសិទ្ធិមនុស្សបានកើតឡើង គឺមិនបាននាំឲ្យមានដំណោះស្រាយអ្វីទេ, ឬពន្យល់ថាហេតុអ្វីច្បាប់ជាតិ និងប្រព័ន្ធយុត្តិធម៌ជាតិ មិនមានភាពយុត្តិធម៌ ឬនឹងមិនអាចទទួលជោគជ័យដោយមូលហេតុផ្សេងៗ។

អង្គការសហប្រជាជាតិក៏បានបង្កើត "ទម្រង់ការពិសេស" សម្រាប់ជជែកអំពីការរំលោភសិទ្ធិមនុស្សផងដែរ។ ទម្រង់ការពិសេសទាំងនេះអាចត្រូវបានប្រើប្រាស់ដោយក្រុមមនុស្ស និងបុគ្គល ដោយមិនចាំបាច់មានការយល់ព្រមពីរដ្ឋាភិបាល និងមិនពឹងផ្អែកលើកតិកាសញ្ញា ឬអនុសញ្ញាផ្សេងឡើយ។

បុគ្គលម្នាក់ ឬសហគមន៍មួយ អាចប្រើប្រាស់ទម្រង់ការពិសេស តាមរយៈការទាក់ទងអ្នកជំនាញសិទ្ធិមនុស្ស ដែលហៅថា "អ្នកបញ្ជូនរបាយការណ៍ពិសេស"។ ពួកគេស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សដែលកើតឡើងក្នុងតំបន់ការងាររបស់ពួកគេ( ហៅថា "អាណត្តិ" ) ដូចជាសិទ្ធិទទួលបានអាហារ សិទ្ធិទទួលបានសុខភាពល្អ ការចាក់កាកសំណល់ពុល ។ល។ អ្នកអាចទាក់ទងអ្នកបញ្ជូនរបាយការណ៍ពិសេសទាំងនេះដោយសរសេរលិខិតសាមញ្ញមួយ ភ្ជាប់ជាមួយរបាយការណ៍ព័ត៌មាន ឯកសារ ឬព័ត៌មានជាលាយលក្ខអក្សរផ្សេងទៀតដែលទាក់ទងនឹងបញ្ហានោះ។ អ្នកទាំងនេះ រាយការណ៍ពីបញ្ហាទាំងនេះទៅកាន់គណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងជូនកាលទៅកាន់មហាសន្និបាតនៃអង្គការសហប្រជាជាតិ។

ឈ្មោះរបស់អ្នកបញ្ជូនរបាយការណ៍, អាណត្តិ, និងព័ត៌មានទាក់ទងរបស់ពួកគេ អាចរកបាននៅក្នុងគេហទំព័ររបស់គណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ( www.ohchr.org ) នៅក្នុងផ្នែកដែលមានចំណងជើងថា "Human Rights by Issue"។

